# ហេតុអ្វីបានជាសហគមន៍ព្រៃឈើមានសារៈសំខាន់?

ការគ្រប់គ្រងព្រៃឈើនៅតំបន់ទេសភាពតាមរយៈសហគមន៍ព្រៃឈើជាយន្តការមួយប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់ការបាត់បង់ និងរេចរឹលព្រៃឈើ ព្រមទាំងរួមចំណែកអភិរក្ស និងស្តារព្រៃឡើងវិញ។ យុទ្ធសាស្ត្រនេះក៏បានលើកកម្ពស់នូវសិទ្ធិប្រើប្រាស់ព្រៃឈើ អភិបាលកិច្ច និងក្របខណ្ឌគតិយុត្ត ដល់ប្រជាជនមូលដ្ឋានក្នុងការទាញយកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ប្រកបដោយសមធម៌ ព្រមទាំងការទ្រទ្រង់បរចិញ្ចឹមជីវិត និងសន្តិសុខស្បៀងផងដែរ។

ទោះបីជាសិទ្ធរបស់សហគមន៍មូលដ្ឋានក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការទទួលបានសេវាកម្ម និងការបែងចែកប្រកបដោយសមធម៌នូវផលប្រយោជន៍ផ្សេងៗ ពីសហគមន៍ព្រៃឈើត្រូវបានទទួលស្គាល់ស្របច្បាប់ និងមានចែងក្នុងគោលនយោបាយជាតិក៏ដោយ ក៏មានចំនុចខ្សោយផងដែរ ដោយសារតែប្រជាជនមូលដ្ឋានមិនត្រូវបានគេបញ្ចូលទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលបានផលប្រយោជន៍ពីព្រៃឈើ។ ទាំងនេះក៏ជាមូលហេតុដែលបណ្តាលឲ្យមានការបាត់បង់ព្រៃឈើ និងបណ្តាលឱ្យប្រជាពលរដ្ឋជួបប្រទះភាពក្រីក្រ និងបង្កើតឲ្យមានជម្លោះ ព្រមទាំងអំពើហឹង្សាក្នុងគ្រួសារផងដែរ។

រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជនបានទទួលស្គាល់ថា ការចូលរួមពេញលេញរបស់សហគមន៍មូលដ្ឋាន ពិតជាមានសារៈសំខាន់ និងប្រកបដោយអត្ថន័យក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងធានាបាននូវសេវាកម្មបរិស្ថានដូចជា ការអភិរក្សជីវចម្រុះ និងការស្តុកកាបូន។ សហគមន៍មូលដ្ឋាន មិនត្រឹមតែជាដៃគូក្នុងការគ្រប់គ្រងព្រៃឈើប៉ុណ្ណោះទេ តែពួកគេដើរតួនាទីសំខាន់បំផុតជំរុញឱ្យការគ្រប់គ្រងព្រៃឈើមានប្រសិទ្ធភាព ដោយសារពួកគេជាអ្នកពឹងអាស្រ័យផ្ទាល់ពីព្រៃឈើ។

បច្ចុប្បន្ននេះ តាមរយៈសហគមន៍ព្រៃឈើ បាននាំឲ្យមាននូវកិច្ចផ្តួចផ្តើមថ្មីៗជាច្រើនទាំងនៅកម្រិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ ដែលនេះមិនត្រឹមតែសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ តែថែមទាំងដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ជនបទលើសេដ្ឋកិច្ចនយោបាយ វប្បធម៌ និងសិទ្ធរបស់ពួកគេ។



## ចូលរួមជាមួយរីខូហ្វ

ចូលរួមជាមួយរីខូហ្វ ដើម្បីលើកកម្ពស់ការប្រើប្រាស់សេវាកម្ម និងផលិតផលរបស់សហគមន៍ព្រៃឈើ ការចុះទស្សនកិច្ចទៅកាន់សហគមន៍មូលដ្ឋាន និងចូលរួមវគ្គបណ្តុះបណ្តាលរបស់យើង។ កត្តាគន្លឹះដែលធ្វើឱ្យរីខូហ្វទទួលបានជោគជ័យគឺការធ្វើការងារជាមួយដៃគូ។ រីខូហ្វស្វាគមន៍ភាពជាដៃគូ និងការគាំទ្រពីដៃគូទាំងអស់ដែលមានគោលដៅដូចគ្នា។ រួមគ្នាធ្វើឱ្យពិភពលោកយើងកាន់តែប្រសើរឡើងសម្រាប់មនុស្ស និងព្រៃឈើ។


ការិយាល័យក្នុងប្រទេសកម្ពុជា
រដ្ឋបាលព្រៃឈើ  អាគារលេខ ៤០
មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ២
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០២៣ ៩៩៨ ៧៨៤
អ៊ីម៉ែល: cambodia@recoftc.org
គេហទំព័រ: www.recoftc.org

ការិយាល័យកណ្តាល
ស្ថិតក្នុងសាកលវិទ្យាល័យ Kasetsart University
ប្រអប់សំបុត្រលេខ ១១១
វិថី Phahonyothin ទីក្រុងបាងកក ១០៩០៣
ព្រះរាជាណាចក្រថៃ
ទូរស័ព្ទលេខ: ៦៦-២-៩៤០-៥៧០០
ទូរសារលេខ: ៦៦-២-៥៦១-៤៨៨០ ឬ
៦៦-២-៥៦២-០៩៦០
អ៊ីមែល: info@recoftc.org


RECOFTC
THE CENTER FOR
PEOPLE AND FORESTS

RECOFTC

THE CENTER FOR PEOPLE AND FORESTS

# មនុស្ស និង ព្រៃឈើ

មានប្រជាជនក្រីក្រភាគច្រើនដែលរស់នៅតំបន់ដាច់ស្រយាលពឹងផ្អែកទៅលើព្រៃឈើក្នុងការទាញយកផល-អនុផលផ្សេងៗ ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ដូចនេះហើយតាមរយៈការបង្កើតសហគមន៍ព្រៃឈើ បានជម្រុញឲ្យប្រជាជនមូលដ្ឋាន ទទួលបាននូវសិទ្ធស្របច្បាប់ ក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព។ លើសពីនេះទៀតសហគមន៍ព្រៃឈើបានជួយពួកគេក្នុងការអភិវឌ្ឍស្ថាប័នមូលដ្ឋាន ដែលនាំឲ្យមានការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងទទួលបានផលប្រយោជន៍សម្រាប់សមាជិកសហគមន៍របស់ខ្លួន។



រ៏ខូហ្វ - មជ្ឈមណ្ឌលសម្រាប់មនុស្ស និង ព្រៃឈើ
RECOFTC - The Center for People and Forests

# តើសហគមន៍ព្រៃឈើជាអ្វី?

សហគមន៍ព្រៃឈើ សំដៅដល់សហគមន៍ដែលស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំជាក្រុម ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ។

ការង្កើតសហគមន៍ព្រៃឈើ ត្រូវមានការចូលរួម និងបម្រើផលប្រយោជន៍ដល់សមាជិកសហគមន៍ទាំងអស់ប្រកបដោយសមធម៌ក្នុងគោលដៅចូលរួមកាត់បន្ថយភាពក្រីក្រ។

សហគមន៍មូលដ្ឋានក្នុងបរិបទនេះរួមមាន ជនជាតិដើមភាគតិច បុគ្គលនីមួយៗ និងសហគមន៍ដែលរស់នៅក្នុង ឬនៅជិត ព្រមទាំងមានទំនាក់ទំនងដោយផ្ទាល់ជាមួយធនធានព្រៃឈើ លើកត្តាសេដ្ឋកិច្ច សង្គម និងវប្បធម៌ជាមួយសហគមន៍ព្រៃឈើដោយផ្ទាល់។

គោលដៅទូទៅក្នុងការបង្កើតសហគមន៍ព្រៃឈើ គឺដើម្បីថែរក្សាមុខងារចម្រុះនៃព្រៃឈើប្រកបដោយនិរន្តរភាព និងដើម្បីលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រជាជនមូលដ្ឋាន ដោយបម្រើតម្រូវការចិញ្ចឹមជីវិតរបស់ពួកគេ។ ការបង្កើតសហគមន៍ព្រៃឈើមានគោលបំណងច្រើនយ៉ាង និងមានទំនាក់ទំនងគ្នាទៅវិញទៅមកនូវ ៖ ការអភិរក្សព្រៃឈើ ថែរក្សាជំនឿប្រពៃណីផ្សេងៗ ផ្គត់ផ្គង់ការប្រើប្រាស់ប្រចាំគ្រួសារ ឬលក្ខណៈពាណិជ្ជកម្ម។ គោលបំណងទាំងនេះជាទូទៅកើតឡើងព្រមគ្នាដោយសារសហគមន៍តែងមានតម្រូវការច្រើនយ៉ាងពីព្រៃឈើ។ សហគមន៍ព្រៃឈើ បានជម្រុញឱ្យអ្នកប្រើប្រាស់ថ្លឹងថ្លែងពីផលប្រយោជន៍ដែលទទួលបាន ប្រកបដោយសមធម៌ និងទាញយកផលប្រយោជន៍ទាំងនេះបានច្រើនយ៉ាង ជាពិសេសសម្រាប់សមាជិកដែលក្រីក្របំផុត។



# សេចក្តីផ្តើម

ព្រៃឈើផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនរស់នៅជនបទ។   ប្រជាជនក្រីក្រភាគច្រើនដែលរស់នៅក្នុងតំបន់ដាច់ស្រយាលពឹងផ្អែកទៅលើព្រៃឈើក្នុងមូលដ្ឋាន ដែលជាប្រភពស្វែងរកប្រាក់ចំណូល និងអាហារទ្រទ្រង់ការរស់ប្រចាំថ្ងៃដូចជា ជ័រទឹកផ្តៅ អុស វល្លិ៍ បន្លែព្រៃ ផ្លែឈើព្រៃ ឱសថ ឬស្សី និងអនុផលផ្សេងៗទៀត។ ប្រជាជនកម្ពុជាជាងពាក់កណ្តាល ពឹងផ្អែកលើព្រៃឈើជាប្រភពចំណូលមួយផ្នែកដែលទ្រទ្រងការរស់នៅរបស់ពួកគេ។ ដូច្នេះហើយការបាត់បង់ព្រៃឈើដោយប្រការណាមួយ មិនត្រឹមតែប៉ះពាល់បរិស្ថានតែប៉ុណ្ណោះទេ វាក៏បណ្តាលឱ្យប៉ះពាលដល់សេដ្ឋកិច្ចរបស់ប្រជាជនក្រីក្រនៅជនបទរាប់លាននាក់ដែលអាស្រ័យផលពីព្រៃឈើផងដែរ។

ការបង្កើតសហគមន៍ព្រៃឈើគឺជាជម្រើសដ៏សមស្របមួយដើម្បីចូលរួមចំណែកទប់ស្កាត់ការបាត់បងព្រៃឈើ និងលើកកម្ពស់ជីវភាពរបស់ប្រជាជន។ បទពិសោធន៍នៃការបង្កើតសហគមន៍ព្រៃឈើលើកដំបូងក្នុងប្រទេសកម្ពុជាចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍ទី៩០តាមរយៈគម្រោងសាកល្បងតូចៗ។ ដោយសារគម្រោងសាកល្បងទាំងនេះទទួលបានជោគជ័យ រាជរដ្ឋាភិបាលបានបន្តដំណើរការនេះដោយបានបង្កើត ច្បាប់ព្រៃឈើ អនុក្រិត្យស្តីពីសហគមន៍ព្រៃឈើ លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ ព្រមទាំងកម្មវិធីព្រៃឈើជាតិបានលេចចេញជារូបរាងឡើងដែលនេះបានផ្តល់ឱកាសដល់ប្រជាជនមូលដ្ឋានដែលអាស្រ័យផលលើព្រៃឈើទទួលបានសិទ្ធស្របច្បាប់តាមរយៈការបង្កើតជាសហគមន៍ព្រៃឈើ។  នេះជាឱកាសសម្រាប់សហគមន៍ជាច្រើនក្នុងការទ្រទ្រង់ជីវភាពរបស់ពួកគេ ព្រមទាំងការពារគម្របព្រៃឈើផងដែរ។

រីខូហ្វ បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើក្នុងភាពជាដៃគូជាមួយ រាជរដ្ឋាភិបាល និងអង្គការដៃគូ។ លើសពីនេះទៀត រីខូហ្វកំពុងបង្កើនការយកចិត្តទុកដាក់ពង្រឹងសិទ្ធិរបស់សហគមន៍នៅក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងដោយមានការចូលរួម ដែលនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ចពិតប្រាកដដល់ប្រជាជនមូលដ្ឋាន និងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។





# ប្រវត្តិសង្ខេបរបស់អង្គការរីខូហ្វ

## រីខូហ្វ - មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ
RECOFTC – The Center for People and Forests

រីខូហ្វ បានចាប់ផ្តើមអនុវត្តគម្រោងអភិវឌ្ឍសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០០៧ ហើយបានបង្កើតការិយាល័យកម្មវិធីប្រចាំប្រទេសជាផ្លូវការនៅឆ្នាំ ២០១០ ដោយផ្តោតជាចម្បងក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើស្របតាមកម្មវិធីព្រៃឈើជាតិ ក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល និងអង្គការដៃគូ។

រីខូហ្វបានគាំទ្រដោយផ្ទាល់ទៅដល់សហគមន៍ព្រៃឈើជាងពាក់កណ្តាល នៃចំនួនសហគមន៍សរុបទាំងអស់ក្នុងប្រទេសកម្ពុជា។ ជោគជ័យនេះសម្រេចបានតាមរយៈការបណ្តុះបណ្តាលការសម្របសម្រួលក្នុងភាពជាដៃគូ និងសកម្មភាពគាំទ្រផ្សេងៗទៀត។

រីខូហ្វ ដើរតួសំខាន់ក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ និងវិស័យព្រៃឈើក្នុងប្រទេសកម្ពុជាហើយជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញតែមួយគត់ដែលមានជំនាញអភិវឌ្ឍសមត្ថភាព ទៅដល់សហគមន៍ព្រៃឈើ។ រីខូហ្វអនុវត្តសកម្មភាពការងាររបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រតភ្ជាប់បណ្តាញ និងការកសាងភាពជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលវិស័យឯកជន សហគមន៍មូលដ្ឋាន គ្រឹះស្ថានអប់រំ និងស្ថាប័នស្រាវជ្រាវ។

រយៈពេលជាង៧ ឆ្នាំនៃបទពិសោធន៍នៅក្នុងប្រទេសកម្ពុជា រីខូហ្វបានរួមចំណែកស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នូវរាល់បញ្ហាផ្សេងៗដែលកើតឡើងក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើតាមរយៈការកសាងសមត្ថភាពដោយរួមមាន៖ ការសិក្សាស្រាវជ្រាវ និងការវិភាគ ការអនុវត្តគំរូសហគមន៍ព្រៃឈើ ព្រមទាំងតាមរយៈការបណ្តុះបណ្តាល។

រីខូហ្វ អនុវត្តការងាររបស់ខ្លួនឈរលើគោលការណ៍សិទ្ធិជាមូលដ្ឋាន ដោយគាំទ្រដល់ប្រជាជនក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង។ ឧទាហរណ៍យើងជឿជាក់យ៉ាងមុតមាំថាការលើកកម្ពស់ការចូលរួមរបស់ស្ត្រីគឺជាសមាសភាពចម្បងក្នុងការគ្រប់គ្រងនិងប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានព្រៃឈើ ព្រមទាំងគាំទ្រដល់គោលការណ៍យុត្តិធម៌សង្គម និងសិទ្ធិមនុស្សផងដែរ។ រីខូហ្វបានប្តេជ្ញាក្នុងការបញ្ជ្រាបទស្សនៈវិស័យយេនឌ័រទៅក្នុងកម្មវិធី និងគោលនយោបាយដើម្បីលើកកម្ពស់សមភាព និងសិទ្ធិនៅក្នុងសហគមន៍ព្រៃឈើ។





## បេសកកម្ម និង ចក្ខុវិស័យ

**បេសកកម្ម:** លើកកម្ពស់សមត្ថភាពប្រជាជនមូលដ្ឋានដើម្បីពង្រឹងសិទ្ធិ អភិបាលកិច្ច និងការទទួលបានផលប្រយោជន៍សមស្រប ពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

**ចក្ខុវិស័យ:** សហគមន៍មូលដ្ឋានចូលរួមក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយ ប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព។

ការអនុវត្តការងារផ្អែកលើគោលការណ៍សំខាន់ៗបីគឺ៖

***សិទ្ធិរឹងមាំ និងសុវត្ថិភាព*** មានសារៈសំខាន់ក្នុងការពង្រឹងមុខរបរចិញ្ចឹមជីវិតនៅជនបទ និងធានាដល់ការការពារព្រៃឈើក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ប្រជាជនមូលដ្ឋានត្រូវតែមានសិទ្ធិកាន់កាប់ច្បាស់លាស់ និងរឹងមាំចំពោះព្រៃឈើ។

***អភិបាលកិច្ចល្អ*** ជាផ្នែកមួយដ៏ចំបាច់ក្នុងការធានាឲ្យមានសិទ្ធិរឹងមាំ និងសុវត្ថិភាព ព្រមទាំងការទទួលបានផលប្រយោជន៍សមស្របរបស់ប្រជាជនមូលដ្ឋាន។ រាល់ការសម្រេចចិត្តទាក់ទងនឹងព្រៃឈើត្រូវធ្វើឡើងដោយមានការចូលរួម មានតម្លាភាព គណនេយ្យភាព និងមានតម្លៃប្រតិបត្តិ។

***ការបែងចែកផលប្រយោជន៍សមស្រប*** ដល់ប្រជាជនមូលដ្ឋានដែលជាលទ្ធផលបានមកពីកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការអភិវឌ្ឍ ការគ្រប់គ្រង និងអភិរក្សព្រៃឈើ។ សហគមន៍ព្រៃឈើផ្តល់ផលប្រយោជន៍ច្រើនយ៉ាងរយៈពេលវែងដល់ប្រជាជនដែលអាស្រ័យផល ខុសពីការគ្រប់គ្រងព្រៃឈើផ្សេងៗទៀតដែលផ្តល់ផលសេដ្ឋកិច្ចក្នុងរយៈពេលខ្លី។

## តំបន់គោលដៅ

រីខូហ្វ កំពុងអនុវត្តការងារនៅក្នុងខេត្តគោលដៅចំនួន១៤ ទូទាំងប្រទេសក្នុងកិច្ចខិតប្រឹងប្រែងចូលរួមចំណែកលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ប្រជាជនមូលដ្ឋាន និងការអភិរក្សធនធានព្រៃឈើតាមរយៈការបង្កើត និងអភិវឌ្ឍសហគមន៍ព្រៃឈើ។ យើងសង្ឃឹមថានឹងអាចពង្រីកសកម្មភាពរបស់យើងទៅកាន់ខេត្តផ្សេងទៀតនៅពេលខាងមុខ។




ផែនទីព្រះរាជាណាចក្រកម្ពុជា

ខេត្តគោលដៅរបស់រីខូហ្វ

# សកម្មភាពការងារ

រីខូហ្វ ផ្តោតទៅលើផ្នែកសំខាន់ៗបួន ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកគឺ៖ ១)សុវត្ថិភាពសហគមន៍ព្រៃឈើ ២)ការលើកកម្ពស់របរចិញ្ចឹមជីវិត និងទីផ្សារផលិតផលសហគមន៍ព្រៃឈើ ៣)អន្តរកម្មរវាងមនុស្សព្រៃឈើ និងការប្រែប្រួលអាកាសធាតុ និង ៤)ការគ្រប់គ្រងទំនាស់ក្នុងវិស័យព្រៃឈើ។ ការងាររបស់យើងរួមមាន៖

- ការស្រាវជ្រាវ និងការវិភាគ
- ការរៀបចំ និងគ្រប់គ្រងគម្រោង
- ការប្រឹក្សាយោបល់ និងការវាយតម្លៃ
- គាំទ្រ និងពង្រឹងសម្លេងរបស់បណ្តាញនៅថ្នាក់មូលដ្ឋាន
- ការចែករំលែកព័ត៌មានតាមរយៈគេហទំព័រ និងបណ្តាញសង្គម
- ការបណ្តុះបណ្តាល
- ការបោះពុម្ព និងការផលិតឯកសារផ្សេងៗ

រីខូហ្វធ្វើការកសាងសមត្ថភាព ដល់អ្នកប្រើប្រាស់ព្រៃឈើ អ្នកអនុវត្តការងារសហគមន៍ព្រៃឈើ អ្នករៀបចំគោលនយោបាយ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល ការរៀបចំទស្សនកិច្ចសិក្សានិងការអភិវឌ្ឍស្ថាប័ន ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងព្រៃឈើពីសំណាក់សហគមន៍។

